# រឿង មាលាដួងចិត្ត

(សរសេរដោយ អ្នកនិពន្ធ នូ ហាច)

## កថាមុខ

ប្រលោមលោកថ្មីដែលខ្ញុំសូមយកមកស្នើជា គ្រឿងកម្សាន្តសម្រាប់អ្នកអានក្នុងពេលនេះ ជារឿងគម្រប់ ទី៤របស់ខ្ញុំ។ ដូចមុនៗដែរ សៀវភៅនេះបានតែងចប់ក្នុងពេលឧត្តមគតិមិនទាន់ ត្រូវទម្ងុះទម្លាយ ជាណាស់ណាពេកទេដោយបញ្ហាជីវិត ពោលគម្រប់២០ឆ្នាំ មកហើយ។ ក្រដៅសំណៅដើមប្រែសម្បុរឡើងលឿងពណ៌ស្ករត្នោត ហើយផុយ របេះដុំៗព្រោះជរាភាព។

ហេតុធំដែលនាំឱ្យខ្ញុំ ស្ទាក់ស្ទើរ យឺតយ៉ាវក្រផ្សាយដល់ម្ល េះមកពីមានបារម្ភក្រែងអ្នកផងលើក តួបុគ្គលខ្លះក្នុងរឿងទៅប្រដូច ឬចោទថាជាផ្នែកជីវភាពរបស់បុរស ស្ត្រីណាមួយ ឬយល់ថា ជាការរិះគន់ចំពោះអ្នកមុខ អ្នកការណាមួយ ទៅវិញ។ ក្នុងចំណុចនេះ ពិសោធន៍នៃរឿង "ផ្កាស្រពោន" បានផ្តល់នូវឧទាហរណ៍ ស្រាប់មកហើយ ព្រោះមានអ្នកអានច្រើនអ្នកបានយល់ច្រឡំ ហើយលើកប្រដូច តួបុគ្គលនានាក្នុងរឿងនោះទៅលើជនដែលមានជីវិតរស់នៅមែនទែន។ ដើម្បី ជៀសវាងមន្ទិលសង្ស័យយ៉ាងនេះទៀត ខ្ញុំបានយល់ថា គប្បីទុកពេលវេលាកន្លង ហួសទៅហើយឱ្យបានវែងឆ្ងាយបន្តិចសិន ក្នុងបំណងបន្សាបការប្រដូចឬអត្ថាធិប្បាយផ្សេងៗ ដែលអាចកើតមានឡើង។

ដូច្នោះខ្ញុំសូមបញ្ជាក់ជូនជាថ្មី ថា សៀវភៅនេះពុំមែនជាប្រវត្តិបន្ទំរបស់ជនរូបណាមួយឡើយ ទោះមានឋា នះក្នុងសង្គមខ្ពស់ឬទាបយ៉ាងណាក៏ដោយថ្វីបើនៅភាគខាងចុងមាន ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រចូលមកជាផ្ទាំងតម្បាញនៃរឿងលើក។ អាស្រ័យហេតុនេះ ប្រសិនបើអ្នកអានសង្កេតឃើញ ឬយល់ថា មានកន្លែងណា សមដូចការពិតខ្លះសូមសន្និដ្ឋានចាត់ជាដំណើរចៃដន្យទៅវិញផងចុះ។

ប្រលោមលោក "មាលាដួងចិត្ត" នេះនិទានបាន ផ្ដើមក្នុងឆ្នាំ១៩៣៩ គឺនៅពេលសង្គ្រាមលោកលើកទីពីរចាប់ផ្ទុលឆេះឡើង ហើយ មកចប់នៅចុងឆ្នាំ១៩៤៦ គឺនៅពេលខេត្តបាត់ដំបង និងដែនដីយើងទាំង ប៉ុន្មានដែលបាត់បង់ទៅនោះ បានវិលត្រឡប់មកចូលរួមក្នុងសហគមន៍ជាតិវិញ។

អ្នកនិពន្ធមានបំណងឱ្យសៀវភៅនេះមានគុណ ភាពជាកញ្ចក់ ឬជាផ្ទាំងគំនូររូបភាពសំរាប់គំនិត និងឧត្ដមគតិរបស់ យុវជនខ្មែរក្នុងសម័យនោះ។

មានហេតុមួយទៀតដែលនាំឱ្យខ្ញុំប្រតិស្ឋ រឿង "មាលាដួងចិត្ត" នេះ។ អ្នកអានយ៉ាងក្រាស់ក្រែលមាននារីជា ភាគច្រើន បានបន្ទោសខ្ញុំថា ចិត្តអាក្រក់ណាស់ដោយបណ្ដោយឱ្យនាងវិធាវី ក្នុងរឿង "ផ្កាស្រពោន" ស្លាប់បាត់បង់ជីវិតទាំងក្មេងខ្ចី ហើយ ស្លូតត្រង់ផង។ ខ្ញុំសរសេររឿងថ្មីនេះក្នុងបំណងចង់លុបលាងនូវ ការរិះគន់បែបនេះទៀត តើសម្រេចដូចប្រាថ្នាមែនឬយ៉ាងណា សូមមិត្ត ទាំងឡាយមេត្តាវិនិច្ឆ័យផងចុះ។

សរុបសេចក្ដីទៅ សៀវភៅរឿងនេះដែលបរិបូណ៌ ដោយយុវភាព ហើយដែលពិពណ៌នាអំពីគំនិត និងឧត្ដមគតិនៃយុវជនក្នុងអំឡុង ឆ្នាំ១៩៣៩-១៩៤៦ សូមយុវជនយើងជំនាន់ក្រោយទុកជាសក្ខីភាពមួយនាកាលសម័យ នោះ។

ខ្ញុំសូមឧទ្ទិសសៀវភៅនេះចំពោះ វិញ្ញាណក្ខន្ធ លោក ឃួន នៅ ជាបិតានិងលោកឱរ ស៊ិន ជាឪពុកធំដែលលោកបាន ណែនាំខ្ញុំឱ្យស្រឡាញ់អក្សរសាស្ត្រតាំងពីកុមារភាពហើយចំពោះយុវជន យើង វីរបុរសយើងដែលបានបូជាជីវិតដើម្បីមាតុភូមិ។

# វគ្គទី១

## វិទ្យាល័យ គ.ស១៩៣៩

ដូចជាពិបាកគិតដែរ!... មិនដឹងជាចាប់ និយាយពីត្រឹមណាទេរឿងនេះ ព្រោះមានរាង និងភាពដូចពពក មានពណ៌ចម្រុះ ដូចឥន្ទធនូ ហើយមានមាឌនិងកម្ពស់កម្ពស់ប៉ុនយក្សា។

ក្នុងដួងចិត្តយុវជនអាយុម្ភៃឆ្នាំ អារម្មណ៍ដ៏អស្ចារ្យនេះ ជួនណាបោកបក់ជាព្យុះជួនណាផាត់ផាយជា ខ្យល់ជំនោរ។ ទុក្ខ និងសេចក្ដីសង្ឃឹមតែងផ្លាស់វេនគ្នាក្នុងសតិមួយ ដែលមានគំនិតវែងឆ្ងាយ តែស្រួយដូចពពុះសាប៊ូដែលអណ្តែតត្រសែត មួយសន្ទុះ លំអដោយឆព្វណ្ណរង្សីចាំងឆ្នុះទៅលើ។

ឱ ! ឆ្នេរសមុទ្រដែលបរិបូណ៌ដោយ ក្លិនក្រអូបឈូលដែលវិចិត្រដោយកូនខ្ទមជ្រកក្រោមដើមដូងល្វន់ ល្វៃ មានកម្រងវល្លិផ្កាប៉ុំស្រោបដូចហត្ថានាងនាដកា។ វាយោហើរពី ផ្ទៃសាគរមកយោលផ្លូងធម្មជាតិ ឱ្យមានចលនាទន់ភ្លន់ រួចហើយក៏តាំងដឹក នាំទៅឆ្ងាយនូវពិដោរឈ្ងុយឈ្ងប់។

ទេសភាពត្រកាលនេះ មាននាទីជាអង្រឹង សម្រាប់យោលរំសាយទុក្ខនៃយុវជនដែលស្រវឹងដោយឃ្លោង ដោយកាព្យថ្វាដូច ចរណៃហើយស្អាតដូចពន្លឺព្រះចន្ទពេញបូណ៌មី។ កវីនិពន្ធដ៏មានពាក្យពិ រោះ ហាក់ដូចជាកើតពីទេពកោសល្យដែលត្រាំនៅក្នុងទុក្ខព្រួយ ហើយរមែង ក្តោបស្រោបនូវវិការដ្ឋាននៃជីវិត បរិបូណ៌ទៅដោយ ការប្រយុទ្ធ ការដណ្តើមស្មើរស៊ីសាច់គ្នា។

អាត្មនជរាព្រលឹងរេចរឹលអាចរត់ចូលជ្រក បានក្នុងសាសនាប៉ុន្តែអាត្មនក្មេងចិន្តានឹងរកកំពង់ផែចូលសម្រាក បានតែក្នុងកាមារម្មណ៍។

គិតសព្វៗទៅ សេចក្តីស្នេហាជាសាសនាមួយបែប ដែរសម្រាប់យុវជន ព្រោះរមែងមានសទ្ធា មានជំនឿ មានសេចក្តីទុកចិត្តទៅ វិញទៅមកៗតែសាសនានេះចាស់ៗបែរជាមិនយល់ដោយភ្លេចសូន្យឈឹង ថាកាលពីដើមមក ខ្លួនធ្លាប់ក្មេងដូចគ្នាដែរទេតើ ហេតុដូច្នេះហើយបានជាចាស់ៗទាំងនោះ តែងកាន់គំនិតរឹងត្អឹង កាន់លទ្ធិសម្បូរជ្រោសិទ្ធិចំពោះបំពង់ត្រួយ ខ្ចីនៃមនុស្សជាតិ។

គួរយើងគិតថា ផ្កាក្រូចពោធិ៍សាត់មាន ក្លិនក្រអូបជាងផ្លែវាដែលទុំលឿងផូរៗ យ៉ាងនេះហើយបានជាយុវជនអាច គ្រេបឱជារសជីវភាពបានជាជាងមនុស្សរសៀល ដែលជាហេតុនាំឱ្យ មាណព និង មាណវី មានទីតាំងជិតជាងក្នុងគោលបំណង ព្រះកាមទេព។

គំនិតវិពណ៌នាខាងលើនេះ ជាយោបល់ របស់ក្មេងៗដែលរៀននៅវិទ្យាល័យស៊ីសុវត្ថិក្នុងសម័យមុនកើត សង្គ្រាមលោកលើកទីពីរ។ យុវជនទាំងនោះយល់ដោយខុស ហើយអយុត្តិធម៌ខ្លះ ផង ក៏ពុំដឹងថាចាស់ៗសង្កត់សង្កិនព្រលឹង និងចិន្តារបស់ខ្លួន ហើយថែមទាំងបំពុលសេចក្តីត្រេកត្រអាលទៀតផង។

គិតខុសក៏ដោយ ត្រូវក៏ដោយ ក្មេងៗបើយល់ យ៉ាងណាហើយតែងដួញចិត្តធ្វើឱ្យគំនិតនោះបានសម្រេច បានពិតប្រាកដដោយ សកម្មក្រៃលែង។ ដើម្បីផាយយល់នូវមនោសញ្ចេតនាផ្សេងៗដែលរមែងកញ្ជ្រោក បោកបោះអាត្មនយុវជននោះ ទើបសូមនាំរឿងនេះមកនិទានដូចតទៅ៖

ថ្ងៃអាទិត្យ! អរុណចាប់លាបពណ៌ក្រហមទុំ ទៅលើជើងមេឃខាងកើត។ ក្នុងសយនដ្ឋានមួយនៃវិទ្យាល័យស៊ីសុវត្ថិដែល សេចក្តីស្ងប់ស្ងាត់គ្របដណ្តប់នៅឡើយ ព្រោះមិនទាន់ដល់ម៉ោង សម្លេងខ្សឹប ខ្សាវចាប់ព្ទខ្សៀវៗពីត្រង់នេះបន្តិចត្រង់នោះបន្តិច។ មាត់មាន់រងាវ បង្អួសបែបបទវែងអន្ទាយក្នុងពន្លឺស្រាងៗនៃព្រហាម។ សេះសំគមដែលទាញ រទេះដឹកបន្លែមួយអន្ទើ និងស្បែកជើងឈើចិនកន្តាំងបាននាំគ្នាវាយផ្ទៃ ថ្នល់ចាក់ជ័រឮសូរក្លិបផ្ទាប់ៗ ឮ

ក្រោកក្រាក។ កង់ទ័ពក្អែកចេញពី ទ្រនុំដើមអម្ពិល ខ្វកកេកកាក។ លាន់រំពងហើយហើរព្ដោះទៅទិសខាងលិចដែល ពំនូកពពកធំៗ ដេកទ្រមក់ត្រាំក្នុងកម្ពិលច្រអូសនៅឡើយ។

មួយសន្ទុះក្រោយមក ស្គរអ្នកយាមទ្វារ ពេទីកម្រើករំជួយអាកាសពណ៌ខៀវនៃព្រឹកព្រហាម ហើយសូរសព្ទ ហ៊ោកញ្ជ្រៀវក៏ផ្ទុះឡើងដូចចិនអុជផាវសែនអ្នកតា។ អ្នកខ្លះចាប់ប្រយុទ្ធនឹងសង្កើចដោយយកស្បែកជើងឈើវាយបំពៀចបច្ចាមិត្រដែលបាន ស្រូបយកឈាមពីពេលយប់ទៅលើក្ដារគ្រែឮផូងផាង។ ក្នុងសម័យនោះមិនបាន ស្គាល់ច្បាស់នៅឡើយទេ នូវការប្រើម្សៅដេដេតេសម្រាប់សម្លាប់សត្វ ល្អិត។ អ្នកខ្លះទៀតប្រជុំគ្នាសប់បាល់ឡុងពូកិត។ ហើយមួយពួកផ្សេង ដទៃ ក្រមាមួយវណ្ណនៅចង្កេះនាំគ្នាប្រមូលខោអាវយកទៅបោកនៅ ក្បាលម៉ាស៊ីនទឹកក្រោយដំវត្តារ។

សូរទ្រហឹងអឹងអាប់បានដាស់ ទីឃាវុធ ភ្ញាក់ ពីដំណេកក្រោកឡើង ប្រមូលក្រសោបជើងមុងពាក់ទៅលើដំបូលរួច ហើយក៏តាំង អង្គុយសញ្ជប់សញ្ជឹងនៅលើគ្រែដោយមានមុខស្ងួតស្ងប់ក្មេងកម្លោះនេះ នឹកគួចដល់នារី ដែលកាលពីល្ងាចមិញវិទ្យុបាននាំមកនូវសម្លេងថ្លាដូចកែវទិព្វ។ នៅជិតសយនដ្ឋាន គឺនៅម្ខាងវិថីប្រូង់ស្វាងហ្វុងតែ ន អ្នកម្ចាស់ផ្ទះមួយបានបើកស្ដាប់ចម្រៀងសិល្បការិនីសៀមពីរោះទន់ ល្ហើយ។ គឺសម្លេងនេះហើយដែលមកប្រលោមបំពេរអាត្ម័ន ទីឃាវុធ ដែល ស្រេកឃ្លាននូវកាមារម្មណ៍។ ថៅមាណពស្ដាប់ពុំបានច្បាស់នូវទំនុកច្រៀង ទេតែសាច់ពិរោះ ដែលមានផ្លត់ទូលាយល្ហឹងល្ហើយ បានគួចព្រលឹងឱ្យអណ្ដែតអណ្ដូងក្នុងរមណីយដ្ឋានមួយនាវិមានសួគ៌ាល័យ។

## វគ្គទី២

សៀវភៅដាក់លើដើមទ្រូង ទៀនលើក្បាលដំណេកឆេះចោលទទេ អ្នកកម្លោះតែងបង្ហើរគំនិតទៅទីឆ្ងាយដោយមនោរម្យ។ បិតក្នុងសភាពយ៉ាងនេះ ចិន្តាតែងនឹកគួចពីចម្ងាយនូវសោភណភាពនៃសិល្បការិនី។ ម្ទេះសមនឹងនាងមានមុខមូលពេញ មានភ្នែកខ្មៅថ្លាយង់ដែលមានរោមត្របកភ្នែកទន្ទ្រាំចាំការពារមានសក់ខ្មៅរលើបទម្លាក់រលក អង្គាញ់មកលើស្មាពណ៌សណ្ដែកបាយ ហើយជារនាំងសម្រាប់កញ្ចឹងកដែលកម្រើកចុះឡើងដោយសមសួនធ្វើឱ្យក្បាល រេរាគួរឱ្យគយគន់ បីដូចដើមស្នោយោលផ្កាលឿងឆ្អិនក្នុងក្រសែខ្យល់ដំនោរ។ ម្ទេះសមនាងមានបបូរមាត់ពណ៌ផ្កាឈូកដែលបិទហើយបើក ដើម្បីបង្ហាញឱ្យឃើញធ្មេញសថ្លាដូចផ្កាម្លិះលា។ ម្ទេះសមនៅលើទ្រូងអាវព្រៃ សាច់ម៉ដ្ឋខៃ កាត់ដេរឡើងប្រណិតទុកឱ្យស្មានៅរាងប៉ោងក្បំលើឱ៉ា នាងពាក់បណ្ដោងពេជ្រដែលដេញរស្មីភ្លើងភ្លឺពព្រាយ។

ទីឃាវុធ ស្ដាប់សម្លេងច្រៀងក្នុងរាត្រី ហើយស្រមៃឃើញជាក់ច្បាស់ដូចទល់មុខគ្នានូវរូបឆោមនារីដែលមានសម្ដីពិ រោះក្រអៅ។ សិស្សលីសេមិនដែលគិតដល់ម្ដងណាសោះថា រមណីវត្ថុនេះអាចចេញបានជារូបរាងមួយដែលធម្មជាតិពុំមានសប្បុរសធម៌ ដើម្បីតុបតែងយ៉ាងនោះទេ។ បើអ្នកណាចង់ភ្នាល់ក៏ ទីឃាវុធ ហ៊ានភ្នាល់ដែរ សម្លេងបរិសុទ្ធឥតមន្ទិលឥតស្រាំ ឥតធារយ៉ាងនេះប្រាកដជាពុំមែនចេញពីអង្គខ្លួនក្រងឹងក្រងង់បានឡើយ! កំពុងតែយល់សប្ដិទាំងភ្នែកបើកយ៉ាងនេះស្រាប់តែវិទ្យុឈប់ស្ងាត់ឈឹង អន្ទះអន្ទែងក្រហាយក្រហល់ក្រៃលែង ទីឃាវុធ បិទសៀវភៅគណិតសាស្ត្រដែលខ្លួនមានបំណងបញ្ចប់មេរៀនមួយហើយចាប់កម្រងកវីនិពន្ធមកអានវិញ។ នាយកម្លោះបើកក្របជញ្ជក់ម្ដងទៀតនូវសាច់កាព្យ "ឡឺសូល" របស់អ័លហ្វ្រិដដឺមុស្សេត៍។ មួយសន្ទុះក្រោយមក លុះបានផ្ចុំពន្ធត់ទៀនរួចស្រេចហើយ សេចក្ដីលង់លក់ក៏ស្រូបគំនិតចិន្តាចៅមាណព ទៅក្នុងសកលសុបិន្តយល់សប្ដិ។

ប៉ុន្តែនៅព្រឹកថ្ងៃអាទិត្យ កម្ទាំងដែលភ្ជាប់អង្គុយ ទីឃាវុធ យ៉ាងយូរនៅលើគ្រែពីវិការដ្ឋានដែលវិញ្ញាណប្រតិស្នូឡើងក្នុងពេលដែល ដេកលក់។ ថ្វីបើដឹងថាជាការភ្ញូតកុហក ថ្វី

បើជាក្តីសង្ឃឹមក្មេងក្ងាយដែលភ្លឺព្រោងព្រាយតែមួយភ្លែតដូច ផ្ទេកបន្ទោរតែកម្មោះយើង នៅតែសញ្ជឹងគិតទៅរកដោយសប្បាយផង ឈឺអួលផ្សាផង។ ជាប្រក្រតីសុបិន្តនិម្មិតជាតំណ នៃប្រាកដនិយម។

យល់សប្តិនោះបានបន្ទប់ ទីឃាវុធ ថាមានរថយន្តដំបូលផ្ទឹតដែលមាននារីទីត្រួយ ចិត្តជាអ្នកបើកបរ ឯខ្លួនអ្នកកម្លោះឯងអង្គុយនៃបនិត្យក្រេបជារសសុកមង្គលល្អ រកនិយាយ ពុំបាន។ រថយន្តបង្វិលខ្លួនធូរខ្សៀកលើថ្នល់ចាក់ជ័រដែលមានគគីរខ្ពស់ត្រសៃ ដុះអមហៃ សងខាង។ លុះដល់ទីថ្នល់ខ្វែងប្រទាក់គ្នា ឡានបត់តម្រង់ទៅរកភ្នំដែលព្រះអាទិត្យពេល ល្ងាចកំពុងយកមាសស្រោបលើ កំពូល។ លលកមួយគូផ្អើលនឹងឡាន ស្ទុះហើរយ៉ាងលឿន ដោយទទះស្លាបញាប់ខ្ញាញ់។ ទីឃាវុធ ក៏យកដៃទៅបបោសអង្អែលស្មានៃឆោមស្និទ្ធ។

រថយន្តឈប់គៀកនឹងជើងភ្នំដ៏មានថ្មធំៗ ដែលភ្លៀងនិងធាតុអាកាសបានឆ្លាក់ជារូប សត្វរស់នៅក្នុងសម័យបុព្វ ប្រវត្តិសាស្រ្ត។ គូសង្សារទំនើបអង្គុយលើថ្មដារមួយផ្ទាំងនៅចំ ពីមុខបឹងទឹកថ្លាដែល ក្នុងទីនោះ ព្រះសុរិយាកំពុងទាញពន្លត់នូវកាំរស្មីរបស់ខ្លួនម្តងមួយ។ ប្របកផ្កាព្រលឹតដែលរីករហង់ក៏ញាប់ញ័រព្រឺព្រួច ព្រោះសុភីវាតបក់មកថ្នាក់ថ្នម។ កូនត្រី រស់ល្អិតៗពណ៌ក្រហមរឆាលនៅហែបហែលចន្លោះដើមស្មៅ ដែលកំពុងយោលបង្អួតគ្នានូវ ចង្កោមផ្កាលឿងឆ្អៅ និងត្រកួនផ្កាពណ៌ស្វាយដែលកំពុងបោះដៃរកគ្នារវាម។ រនាលស្លាប ពណ៌ជម្ពូខំរំពៃរកធ្មក់មច្ឆាជាតិនៅរបមាត់បឹង ដើម្បីជាអាហារបង្អើយមុនពេលវិលរកទ្រនំ។ មួយសន្ទុះក្រោយមក បក្សីជើងវែងស្ទុះហើរទាំងគូៗ ឆ្ពោះទៅទិសខាងលិច ឯអាកាលក៏ធ្លាក់ ត្រជាក់ស្រឹត។

"ទិនករល្អថ្វាលោយសូន្យសល់តែម្ញប់ ក្រអូបឈ្ងួល" ទីឃាវុធ ខ្សិបកាព្យនេះរបស់កវី បារាំងម្នាក់ ដែលខ្លួនពេញចិត្តហើយស្ញើចក្រៃលែង។ ហ្វូងជ្រឹងចេញពីគុហាភ្នំយកស្លាបល្អិត ជ្រាយវាយអាកាសប្រផេះនៃ រាត្រីកាល។ ដោយមានសត្វនេះមួយហើរឆាបមកជិតនាងពេក យុវតីតក់ស្លុត គេចរកជម្រកពួនភ័យនាដើមទ្រូងនៃនាយកម្លោះ។

មកដល់ត្រឹមនេះសុបិន្តក៏អន្តរធានបាត់ ទុកឱ្យ ទីឃាវុធ អល់ឯកព្រោះសុភមង្គលស្រពិចស្រពិលនេះ នាំឱ្យសោប់សេល់ខ្វល់ក្នុងចិត្តពន់ប្រមាណ។

## វគ្គទី៣

ទីឃាវុធ ជាសិស្សឧស្សាហ៍ មានប្រាជ្ញាឈ្លាសវៃនៅថ្នាក់ទីពីរនៃមធ្យមសិក្សា។ អ្នកកម្លោះចូលចិត្តរៀនជីវភាសាណាស់ ហើយតែងបានលេខបានទីល្អៗក្នុងវិជ្ជាភាសាអង់គ្លេស បារាំង និងខ្មែរ។ មួយទៀតដោយបានជាវចនានុក្រមបារាំង សៀមមួយក្បាលមកទុកមាណពក៏ខំសិក្សាភាសាជិតខាងនោះទៀតក្នុងឱកាស ទំនេរ។ ដូចខ្មែរទាំងពួងដែរ អ្នកកម្លោះតែងសរសើរថាភាសាសៀមមានសម្លេងពិរោះ។ ហេតុនេះហើយបានខំព្យាយាមទាល់តែអានសៀវភៅបានខ្លះ ថ្វីបើនៅរឹងមាត់និយាយពុំសូវច្បាស់ ព្រោះដាក់ខ្យល់ខ្ពស់ទាបពុំត្រូវ។

ប៉ុន្តែសិស្សនេះពុំសូវចូលចិត្ត វិទ្យាសាស្ត្រទេ។ ក្នុងពេលរៀនរូបសាស្ត្រ ឬគណិតសាស្ត្រ ព្រលឹងតែងអណ្តែតអណ្តូងទៅឆ្ងាយ។ មួយទៀតពាក្យដែល ទីឃាវុធ និយាយច្រើនដូចក្នុងសៀវភៅពេក បានជាសាស្ត្រាចារ្យខាងវិទ្យាសាស្ត្រតែងស្តីបន្ទោសជាញឹកញាប់ថាខ្វះសេចក្តីជាក់លាក់។ ទោះជាយ៉ាងនេះក៏ដោយ អ្នកកម្លោះតែងព្យាយាមណាស់ ហើយចាត់របៀបប្រើពេលយ៉ាងទៀងទាត់។ ថ្វីបើទើបតែចាប់រៀនអង់គ្លេស តែអាចនិយាយភាសានេះបានខ្លះ ហើយអានទស្សនាវដ្តីអាមេរិកកាំង ឬប្រលោមលោកអង់គ្លេសក្នុងការប៉ូលីស ឬផ្សងព្រេងបានធូរបង្គួរ។ ជាធម្មតាក្មេងនេះអានទាំងអស់មិនថាអ្វីជាអ្វីទេ ចេះតែចង់ដឹង ចង់យល់ជានិច្ច។ បើគេនិយាយអំពីនយោបាយក្តី រឿងកុនក្តី អក្សរសាស្ត្រក្តី ទីឃាវុធ ចេះជូនយោបល់ ចេះអធិប្បាយដោយពិរោះ ហើយអ្នកផងចូលចិត្តស្តាប់ណាស់ដោយឃើញថា ជាក្មេងមានគំនិតជ្រៅ មានចិត្តទន់ ពួកម៉ាកទាំងឡាយតែងស្មោះស្ម័គ្ររាប់រកដោយសមានចិត្ត ប្រសិនបើទៅពើបលើមជ្ឈដ្ឋានមួយថ្មី ទីឃាវុធ សម្ងឹងហើយស្តាប់មួយសន្ទុះ ក៏ថ្ងឹងឈ្វេងយល់ភ្លាមថា ពពួកជននោះមានប្រាជ្ញាត្រឹមនេះ ជម្រៅត្រឹមនោះ។ តមកក៏តាំងលៃ

សំដីប្រមាណពាក្យឱ្យបានសមល្មម តែអ្នកទាំងនោះរីករាយចង់ស្ដាប់។ ទោះនៅចំពោះមុខមនុស្សមានកិរិយាយ៉ាងណាក៏ដោយ អ្នកកម្លោះចេះរកពាក្យមកថ្លៃងកម្សាន្តលេងបានពុំខានឡើយ។ ទាំងនេះ ត្បិតមានបំណងតែមួយ គឺមិនចង់ឱ្យអ្នកផងឈឺចាប់ ឬថ្នាក់ថ្នល់ក្នុងចិត្តដោយសារខ្លួនព្រោះខ្លួនសោះឡើយ។

ទីឃាវុធ ជាអ្នករហ័សខឹងបន្តិច ប៉ុន្តែចេះទប់មាត់ទប់កបាន មិនឱ្យក្លាយទៅជាច្រឡោតដល់ទៅស្រែកឡូឡានោះទេ។ បើឃើញមិត្តណាចេះស្រាកស្រួលនឹងខ្លួន ចៅមាណពយើងមានចិត្តរីករាយនឹកគុណគេពុំភ្លេចទេ តែបើគេធ្វើព្រងើយកន្តើយ ឬរំលោភត្រង់ណា ចិត្តអ្នកកម្លោះក៏ថ្នាក់ថ្នល់ធ្នាន់ធ្នាញ់មិនងាយនឹងរសាយបានឡើយ។ ក្នុងពេលរៀបចំមុខកិច្ចការសិក្សា ទីឃាវុធ ខំផ្ចិតផ្ចង់មិនឱ្យពួកម៉ាកកើតរំខានដល់ខ្លួនសោះ ចំណែកខ្លួនវិញក៏មិនអត់ឱនដល់កៀនណាដែលធ្វើឱ្យមានអំពល់បានឡើយ។

ទីឃាវុធ ចូលចិត្តករីនិពន្ធបារាំងណាស់ តែមិនស្រឡាញ់ពួកបុរាណលើសពួកទំនើបទេ ឱ្យតែរបស់ទន់ត្រជាក់បរិបូណ៌ដោយមនោសញ្ចេតនាចុះមុខជាវាប់អានពុំខាន ឡើយ។ សិស្សនេះតែងសេចក្ដីបានយ៉ាងធូរ បើកាលណាត្រូវការនិយាយពីដួងចិត្ត ពីមនោសញ្ចេតនា។ ប៉ុន្តែសាច់និពន្ធប្រែជារដិបរដុបទៅវិញ ក្នុងពេលដែលនិយាយអំពីការណ៍អ្វីដែលមានគ្រាតគ្រើម។ ក្នុងវិស្សមកាល អ្នកកម្លោះតែងសរសេរសំបុត្រជាច្រើនច្បាប់មានសេចក្ដីទន់ភ្លន់ទៅរក មិត្តសំឡាញ់។ ប្រសិនបើអ្នកនោះឯង ថ្ងោះធ្លោយពុំបានតបវិញទេ មុខតែ ទីឃាវុធ រងសេចក្ដីឈឺចាប់ក្រៃលែង។

មួយទៀត ចៅមាណពចេះលើកកំណាព្យស្រងេះស្រងោចបរិបូណ៌ដោយសេចក្ដីស្នេហា។ ចំពោះគុណជាតិនេះ អ្នកកម្លោះបានក្រេបសោកណភាពតែដោយសៀវភៅ ដោយប្រលោមលោក និងដោយភាពយន្តប៉ុណ្ណោះ។ ទីឃាវុធ តែងអានដោយចាប់ចិត្តនូវរឿងនានាដូចជា "ទ្វារចង្អៀត" របស់អង់ដ្រេហ្ស៊ីដ និង "ប្រិយនារី" របស់រ៉ូដ្ហាយែរ ជាដើម។ មិនថាទេ បើអ្នកនិពន្ធមិនសូវប្រសប់តែងពាក្យ គ្រាន់តែធ្វើឱ្យទាក់ចិត្តចុះ មុខជាវាប់អានពុំខាន

ឡើយ។ ក្មេងកម្លោះនេះអានញាប់ណាស់ រហ័សណាស់ ជួនកាលជក់រឿងពេកក៏បញ្ចប់សៀវភៅក្រាស់បង្គួរតែក្នុងមួយយប់។

រាល់រសៀលថ្ងៃអាទិត្យ ទីឃាវុធ តែងចេញពីសាលាដើម្បីទៅរកមើលកុន។ ក្នុងពេលនោះអ្នកកម្លោះតែងផ្ទៀងឃ្លាំឆាកណា ដែលប្រកបដោយសេចក្ដីស្នេហាយ៉ាងត្រកាល ដូចគូរសង្សារជិះទូកលេងក្នុងបឹងឬលំហែដោយរថយន្តដែលបរកាត់ទេសភាព យ៉ាងចាប់ចិត្ត។ ញញឹមដែលរីកពព្រាយលើបបូរមាត់ស្រស់មួយ តែងធ្វើឱ្យថៅមាណពសប្បាយជាងវិការដ្ឋានអ្វីឯទៀតទាំងអស់។ លុះវិលមកដំណេកវិញ រូបសិល្បនារីទាំងឡាយដែលខ្លួនបានឃើញស្រមោលពីថ្ងៃ ក៏ផុសអណ្ដែតឡើងជាថ្មីក្នុងសេចក្ដីស្រមៃមួយដែលមានវង់រស្មីស្រោប ព័ន្ធពន្ធឺចិញ្ចាច។ ឱ ! កញ្ញាមានឆោមលោមពណ៌ ដូចទេពអក្សរ ដែលបានបញ្ចេញកាយវិការល្វះល្វន់ក្នុងទេសភាពល្អធើតឆាយដូចសួគ៌ាល័យ អនុស្សាវរីយ៍ស្នេហ៍ទាំងនេះ តែងមកស្ថិតនៅពាសពេញក្នុងសេចក្ដីនឹងរលឹករបស់យុវបុរស ហើយធ្វើឱ្យដួងចិត្តគេលេចលង់ទៅក្នុងពិដោរកាមារម្មណ៍ ដែលរសាត់មកពីទីឆ្ងាយ។

ជួនកាល ពេលដើរលំហែបាននាំនាយកម្លោះឱ្យប្រទះឃើញមួយភ្លែត នូវរាងក្លៀវក្លំនៃនារីមួយនាក់។ រូបស្រពិចស្រពិលនេះ បានបណ្ដោយឱ្យមាណពយើងភ័ន្តភាំងស្មារតីជំហានបោះដើរទៅមុខដោយស្វ័យប្រវត្តិ។ ថ្ងៃមួយកំពុងដើរតាមវិថីផ្សារស្រោប់តែមានអារម្មណ៍ថា មានក្រសែភ្នែកសំឡឹងខ្លួន។ ទីឃាវុធ ងើយមើលឡើយលើឃើញនារីចិនម្នាក់សក់សឹងម៉ឺង សាច់ដៃទ្រលុកប្រិត់លើមាត់បង្អួច ហើយបង្ហើរញញឹមទៅទិសមួយដែលទីឃាវុធ ស្មានថាត្រង់មករកខ្លួន។ គ្រាន់តែប៉ុណ្ណោះក៏ព្រលឹងអណ្ដែតអណ្ដូងស្វែងរកការយល់សប្តិ ដើងលែងជាប់នឹងដីទៅហើយ។

មួយទៀត ទីឃាវុធ មិនចូលចិត្តឮសំដីបន្ថោកបន្ទាប ឬបង្អាប់អំពីស្ត្រីភេទទេ តែកាន់ជើងឥត្ថីភាពជានិច្ច ទោះបីខុសក៏ដោយត្រូវក៏ដោយ។ កម្លោះមានយោបល់ថា គួរតែផ្ដាច់នារីខ្មែរឱ្យផុតស្រឡះពីប្រពៃណី។ ប្រសិនបើឃើញស្ត្រីណាមួយប្រព្រឹត្តឆ្គង និងកន្ទង

ចរិយាបថ ទីឃាវុធ តែងថ្នាក់ថ្នល់ក្នុងចិត្តដែរ ប៉ុន្តែមួយសន្ទុះក្រោយមកក៏រកលេសបានមកលើកទោសឱ្យជានិច្ច។

……………………………………………………………………………………………………………

## វគ្គទី៤

នៅព្រឹកថ្ងៃអាទិត្យនេះ លុះបានត្រា ត្រែង សញ្ញាប់សញ្ញឹងក្នុងគំនិតឥតប្រាកដនិយម យ៉ាងនេះអស់ពេលយ៉ាងវែង មក ទីឃាវុធ ក៏ចូលទៅលប់មុខសិតសក់រៀបចំខ្លួនបានស្រស់បស់។ ចេញផុតពីភាព ពាយមាយកាលណា អ្នកកម្លោះក៏ក្លាយជាអ្នកលើចលេងក្អាកក្អាយក្នុងចំណោមពួកម៉ាកជាច្រើននាក់។ លុះឃើញមាណពនិយាយឆ្កាដៃឆ្កាជើងដូច គ្រាឥឡូវនេះ អ្នកផងដែលពុំដែលស្គាល់ពីមុនមកមុខតែមិនអាចស្មាន បានទេ ថាកាលពីកន្ទះម៉ោងមុនគេជាមនុស្សរវើរវាយ។

ក្នុងឱកាសរៀបចំមុខរៀន ទីឃាវុធ ខំ ផ្ចិតផ្ចង់មិនឱ្យល្ងៀងទេ។ នៅលើមែកថ្កូវជិតបន្ទប់រៀន គ្រលីងគ្រលោង ស្រវឹងដោយពន្លឺថ្ងៃ និងសន្តិភាពរបស់ធម្មជាតិច្រៀងឥតគ្នាពុំដាច់ពីមាត់ដែលជាហេតុនាំឱ្យចៅមាណពគួចនឹកព្រួយទៅភូមិកំណើត ដែលជា ភូមិតូចមួយតាំងនៅកណ្ដាលវាលស្រែចម្ងាយជាង១០គ.ម ពីក្រុងបាត់ដំបង តាមផ្លូវថ្នល់ទៅមង្គលបុរី។ មួយសន្ទុះ ទីឃាវុធ នឹកដល់រលកសន្ទូង និង ពព្រោះដែលអង្រាញ់ប្រជេញគ្នាតាមក្រោមរស្មីភ្លឺថ្លានៃព្រះ សុរិយា ឬដល់ដងអូរក្បាលស្រែដែលខ្លួនធ្លាប់នាំគ្នាគ្នីទប់ទឹកបាច ចាប់ត្រី។ កម្លោះគិតឃើញដោយរីករាយថា នៅមិនប៉ុន្មានថ្ងៃទៀតទេនឹង ដល់វិស្សមកាលឈប់ចូលឆ្នាំចិនហើយ។ អែយ៉ា! ខ្លួននឹងបានឱកាសទៅលេង ភូមិកំណើតហើយតើ!

រសៀលថ្ងៃនោះ ទីឃាវុធ ស្លៀកពាក់ស្អាតបាត ហើយចេញពីសាលាទៅដើរជាមួយមិត្តភ័ក្តិតាមវិថីមហាធានី។ បន្តិចក្រោយមក ក៏នាំគ្នានាំចូលទៅញ៉ាំទឹកក្រូចនៅភោជ-នីយដ្ឋាន "កុនសាន" ទំពាំ ពោងកុន "ដេអិន" បើកទ្វារនឹងទិញសំបុត្រចូលមើល។ ពួកយុវជន

ប្ដូរយោបល់ គ្នាដោយប្រៀបផ្ទឹមការប៉ិនប្រសប់អ្នកដើរតួរកុន ស្រី-ប្រុស ហើយសើចធូរស្រួលសប្បាយ ទីឃាវុធ ជូនឧទាហរណ៍ដោយធ្វើត្រាប់អ្នកដើរតួរបារាំង ម្នាក់យ៉ាងក្រមាច់ក្រមើមនាំឱ្យសើចផ្ទុះប្រាវទទួលឡើង។

មិនប៉ុន្មាននាទីក្រោយមក កណ្ដឹងអគ្គិសនីរោង "ដេអិន" រោទិ៍រន្ទាន់ ឯទ្វារដែកខាងមុខក៏បើកញែកជាពីរផ្នែករួចចូលគៀន។

ទីឃាវុធ ក្រោកឈរឡើងស្មើនឹងគេដែរ ក៏ ឧទានៈ នៅតែមួយអាទិត្យទៀតទេ យើងដល់ពេលឈប់ចូលឆ្នាំចិនហើយ...... មកដល់ត្រង់នេះ អ្នកនិពន្ធសូមបើកវង់ក្រចកមួយ ដើម្បីសូមឱ្យអ្នកអានអភ័យទោស ដោយបាន ថ្ងៃងរៀបរាប់វែងបន្តិចអំពីបរិយាកាសនៅវិទ្យាល័យស៊ីសុវត្ថិក្នុង ឆ្នាំ គ.ស ១៩៣៩ ហើយអំពីកិរិយាទឹកចិត្តអ្នកកម្លោះ ទីឃាវុធ។ ប៉ុន្ដែអ្នកនិពន្ធយល់ថាជាការចាំបាច់ណាស់ ដើម្បីផាយយល់រឿងដែលហូរល្ហិលតា មនារីនៃជីវិតដែលលើកមកពណ៌នាក្នុងគ្រានោះ។

.........................................................................................................................................

## វគ្គទី៤

## យល់សប្ដិតង់ក្លាយជាការពិតមួយដងមួយកាលដែរ

កាលពីយប់មានភ្លៀងមួយមេធំៗ ភ្លៀងធ្លាក់ក្នុងរដូវនេះ ជាការចំឡែក ដែរមិនសូវមានទេ។ ទឹកល្អក់ខ្វល់កាត់ក្នុងជង្ហុក និងវិថីនៃក្រុង បាត់ដំបង។ នៅពេលបៀបភ្លឺ ទីឃាវុធ ទុំបន្ទិតលើរ៉ូម៉កដែលដឹកវ៉ាលីស ខ្លួនមួយផងបានសំដៅឆ្ពោះទៅស្ថានីយ៍រថភ្លើង ដើម្បីធ្វើដំណើរ កម្សាន្តជាមួយគ្រួសារនាភូមិអូរតាគី ក្នុងអំឡុងពេលឈប់បុណ្យចូលឆ្នាំ រួច អ្នកកម្លោះក៏បានមកស្នាក់អាស្រ័យនៅផ្ទះបងប្អូនក្នុងក្រុងមួយ យប់ ដើម្បីក្រោកមកជិះរថភ្លើងឱ្យបានទាន់ពេលព្រោះត្រូវចេញដំណើរ លពីព្រហាមស្រាង។

យានតូចបានបត់កាច់ចូលតាមថ្នល់ត្រង់ ទៅស្ថានីយ៍។ ផ្លូវនេះមានទឹកដក់តាមក្រឡុកច្រើនអនេក ព្រោះខ្វះការ ជុសជុលជាយូរយារណាស់មកហើយ។ ផ្ទៃថ្នល់ជាភក់ស្អិតដូចបាយម៉ាន។ ស្រាប់តែមានរថយន្តប៊ីហ្វូ ២០២ មួយបរយ៉ាងលឿនជៀសហួសទៅដោយបាចទឹកកខ្វក់មកលើអ្នកដែលវារតើម។ អ្នករ៉ឺម៉កក៏តាំងដេរប្រទេច។ ឯ ទីឃាវុធ បានសម្លឹងមើលលេខឡាន ហើយស្គាល់ជាក់ជារបស់អ្នក សៅវ៉ប្ប។

ស្ត្រីនេះជាប្រពន្ធមួយតួ ក្នុងចំណោម ប្រពន្ធច្រើននាក់ របស់ ពញាគទាធរ អតីតទេសាភិបាលបាត់ដំបងក្នុងសម័យ អាណាចក្រសៀម។ក្រោយមក ក្នុងគ្រាផែនដី "ភ័ន្តប្រែ" បាត់ដំបងត្រូវបានមក រួបរួមក្នុងអាណាចក្រខ្មែរវិញ អ្នក សៅវ៉ប្ប ក៏រត់គៀសខ្លួនជាមួយចង្កោមប្រពន្ធឯទៀត។ ដើម្បីទៅតាមស៊ីបុណ្យ "លោកម្ចាស់" ជាស្វាមីឯ ប្រទេសសៀមទៀត។ ដោយបានរួមវាសនាចែកហ៊ុនគ្នាជាមួយស្ត្រីឯទៀត ផងអ្នក សៅវ៉ប្ប ក៏ទទួលបានកូនស្រីមួយ កូនប្រុសមួយពី ពញាគ ទាធរ មួយអន្ទើ និងទ្រព្យសម្បត្តិជាមរតកយ៉ាងក្រាសក្រែល។ ឥឡូវនេះ អ្នកសៅ វ៉ប្ប រំលៀកខ្លួនត្រឡប់មកចូលដែលកំណើតវិញហើយសង់ផ្ទះថ្មមួយ ស្កឹមស្កៃកំណាចនៅភូមិវត្តលៀប។

អ្នក សៅវ៉ប្ប ក្ដីបុត្រាបុត្រីគាត់ ក្ដីដែលអ្នកបាត់ដំបងហៅដោយគោរពថា "ឃុន" ៗនោះតែងចេញបង្អួតឱ្យ អ្នកផងកោតថា ខ្លួនជាអ្នកមានទ្រព្យ ជាអ្នកអម្បូរខ្ពស់ ហើយជាអ្នកធ្លាប់នៅទីក្រុងធំ។ នៅក្នុងផ្ទះគាត់ដែលតុបតែងដោយវត្ថុច្រើន ស្អែកស្អុះ ឥតសមសួនសោះគឺមានប្រើសុទ្ធតែរបស់ថ្លៃៗឱ្យគេស្ញប់ស្ញែង ដូចជា ផ្តិលមាស ប្រអប់ស្លាមាសជាដើម។ ថ្វីបើគាត់មានអាយុហាសិបប្លាយ ទៅហើយ គាត់នៅស្លៀកខៀវពណ៌ស្រស់ៗមុខគាត់ទទះម្សៅរទូស។ ជើងគាត់ពាក់ ស្បែកជើងផ្លូខ្មៅ ចុងស្រួចហើយងឡើងលើ ហើយគាត់ដើរកៃក្រាយខ្នង បន្ទេរមកក្រោយបន្តិចភ្នែកសម្លឹងទៅឆ្ងាយមានឫកខ្ពស់ក្រអឺតបែបចង់ សម្ដែងឱ្យឃើញថា ដីនេះ ទីនេះ កាលពីដើមម៉ិញជារបស់ប្ដីអញ គឺនៅជា របស់ខ្លួនអញខ្វះដែរ។

ចំណែកឯកូនប្រុសគាត់ ដើងខោព្រៃ ខ្មៅធំៗប៉ុនការុងអំបិល ហើយពាក់អាវព្រៃអន្ទូញតាប្លោកធំៗ ពណ៌ខៀវ ក្រហម ថ្ងៃៗឡើង គិតតែពីបើកឡានដើរដល់ត្រីត្រឹម ឬដល់មាន់ ហើយយប់ៗឡើង ដើរបៃចង់ស្រីជាមួយដៃគូត្បាញអាយពីរ បីនាក់ៗ រីឯ"ឃុន" ស្រីវិញអស្វារ្យហើយ ដឹងតែប្រកឹបតែម្តង ជិះកង់ជិះ ម៉ូតូតែងខ្លួនភោភាវរកគ្នានពីរទេក្នុងដែនបាត់ដំបង! ឃុនឯលិច ឃិន ឯកើត អ្នកដងស្ទឹងសង្កែកាំងស្មារតី ដោយមិនដែលឃើញសោះនូវសេចក្តី ហ៊ីហាចម្ងៃកដល់ម្ងេះឡើយ ត្បិតសម័យនេះពុំដែលមានស្ត្រីមានពូជអម្បូរ ណាហ៊ានជិះទោចក្រក្រយានឡើយៗ

ដកស្រង់ចេញពី GOLD TIPS